ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គិសនីកម្ពុជា
គណៈកម្មាធិការលទ្ធកម្ម
លេខ:...0540.....PC អ.ក

សេចក្តីជូនដំណឹង
ស្តីពីឈ្នួលពលកម្មវិនិយោគ បង្វែរខ្សែបណ្តាញអាកាសឆ្លងផ្លូវជាតិ
លេខ០៦ និងវិថីឡុងឈិន ទៅជាកាបកប់ដីវិញ
ជូននាយកដ្ឋានអាជីវកម្មចែកចាយ

អគ្គិសនីកម្ពុជាសូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានជ្រាបថា: អគ្គិសនីកម្ពុជា នឹង ដាក់ឲ្យពិគ្រោះថ្លៃជាសាធារណៈដើម្បីជ្រើសរើសអ្នកទទួលការងារស្តីពី ឈ្នួលពលកម្មវិនិយោគ បង្វែរខ្សែបណ្តាញអាកាសឆ្លងផ្លូវជាតិលេខ០៦ និងវិថីឡុងឈិន ទៅជាកាបកប់ដីវិញ ជូននាយកដ្ឋានអាជីវកម្មចែកចាយ ។

អគ្គិសនីកម្ពុជាបានរៀបចំឯកសារសំរាប់ ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បី ចូលរួមពិគ្រោះថ្លៃ ។ ឯកសារពិគ្រោះថ្លៃមានដាក់លក់នៅអង្គភាពលទ្ធកម្ម ដែលមានអាសយដ្ឋាន៖ ផ្លូវព្រះយុគន្ធរ សង្កាត់វត្តភ្នំ ខ័ណ្ឌជូនពេញ រាជធានីភ្នំពេញចាប់ពី ថ្ងៃទី២០ ខែកុម្ភ: ឆ្នាំ២០២០ តទៅរៀងរាល់ម៉ោងធ្វើការ(ទូរស័ព្ទទំនាក់ទំនង៖023 67 66 007 និង Website: www.edc.com.kh)។

ឯកសារពិគ្រោះថ្លៃដែលបានបំពេញរួចត្រូវប្រគល់ ជូនអង្គភាពលទ្ធកម្មយ៉ាងយូរបំផុតត្រឹម ថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២០ វេលាម៉ោង ១១ : 00 នាទី។

ការបើកសំណើពិគ្រោះថ្លៃនឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើ ថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២០ វេលាម៉ោង ១៥:00 នាទី។

ក្រុមហ៊ុន/សហគ្រាស ដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬ មានប្រភពតែមួយអាចដាក់សំណើពិគ្រោះថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាស ដែលមានបំណងចូលរួមពិគ្រោះថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារពិគ្រោះថ្លៃ និងសាកសួរព័ត៌មានដែលទាក់ទងនឹងការពិគ្រោះថ្លៃនេះ។

ថ្ងៃ.....ទ្រាំ.....ខែ.....ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
រាជធានីភ្នំពេញ, ថ្ងៃទី...១៨...ខែ...កុម្ភ:...ឆ្នាំ២០២០
ជ. ប្រធានគណៈកម្មាធិការលទ្ធកម្ម

ហង់ ឆូច

ចម្លងជូន៖
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
-អង្គភាពប្រឆាំងអំពើពុករលួយ